# ការបែងចែកប្រភេទរឿងក្តីទាក់ទងនឹងការចុះបញ្ជី

## មូលដ្ឋាននៃ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ" និង "សេចក្តីសម្រេចបញ្ចប់" ១



ការិយាល័យស្រាវជ្រាវនីតិកម្មរួម ផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌

សាស្ត្រាចារ្យច្បាប់ UCHIYAMA Jun

# 【ប្រភេទរឿងក្ដីដែលត្រូវបង្ហាញ】

១ ការទាមទារឲ្យផ្ទេរការចុះបញ្ជីដោយផ្អែកលើកិច្ចសន្យា

២ ការទាមទារឲ្យលុបការចុះបញ្ជី

មូលដ្ឋាន

---

ការអនុវត្តជាក់ស្ដែង

៣ ការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ(អចលនវត្ថុ)តាមរយៈការលែងលះ

៤ ការទាមទារឲ្យចុះបញ្ជីដោយផ្អែកលើការបែងចែកមត៌ក

# 【ចំណុចដែលត្រូវចាប់អារម្មណ៍】

× គ្រាន់តែចងចាំការសរសេររបស់ឧទាហរណ៍

↓

មិនអាចដោះស្រាយករណីសិក្សាដំបូងទេ

○ យល់ទៅលើមូលហេតុនៃការសរសេររបស់ឧទាហរណ៍

↓

ទោះបីជាករណីសិក្សាដំបូងក៏អាចដោះស្រាយបានដែរ

នឹងក្លាយជាសាលក្រមត្រឹមត្រូវសម្រាប់ការចុះបញ្ជី

# 【ប្រភេទរឿងក្ដីដែលត្រូវបង្ហាញ】

១　ការទាមទារឲ្យផ្ទេរការចុះបញ្ជីដោយផ្អែកលើកិច្ចសន្យា

២　ការទាមទារឲ្យលុបការចុះបញ្ជី

៣　ការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ(អចលនវត្ថុ) តាមរយៈការលែងលះ

៤　ការទាមទារឲ្យចុះបញ្ជីដោយផ្អែកលើការបែងចែកមត៌ក

# 【ករណីសិក្សាទី ១】

# ការលក់ ឧិញ

## (ការលុបចោលដោយសារការតាន់ច្រឡំ)

ករណីសិក្សាទី ១

# ការលក់ទិញដី



A → B



ចុះបញ្ជីកម្មសិទ្ធិ

| | |
|---|---|
| ទីតាំង | សង្កាត់បឹងកេងកង ១ រាជធានីភ្នំពេញ |
| ទំហំ | ៦០០ ម$^{២}$ |
| ថ្ងៃចុះកិច្ចសន្យា | ថ្ងៃទី២៩ មករា ២០១៣ |
| តម្លៃ | ៦០ម៉ឺនដុល្លារ |






ប្រាក់

ករណីសិក្សាទី ១

# ការលក់ទិញដី



ករណីសិក្សាទី ១

# ការលក់ទិញដី




វាមិនត្រឹមត្រូវទេ !

សូមចូលរួមសហការចុះបញ្ជីផ្ទេរ !

ករណីសិក្សាទី ១




ដាក់ពាក្យបណ្ដឹង !
(ទាមទារឲ្យចុះបញ្ជីផ្ទេរ)

ករណីសិក្សាទី ១



A



B



B ជាអ្នកឈ្នះ !

# [ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ／សេចក្ដីសម្រេចបញ្ចប់]

បង្គាប់ឲ្យចុងចម្លើយ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលបានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទដោយមូលហេតុនៃការលក់ទិញចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៣។

ប្រសិនបើធ្វើការវិភាគ…

១ "ចុងចម្លើយ"

២ "ទៅឲ្យដើមចោទ"

៣ "ដីដែលបានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុ"

៤ "ដោយមូលហេតុនៃការលក់ទិញចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣"

៥ "(បង្គាប់)ឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល"

# ១ “ចុងចម្លើយ”

〈មូលហេតុ〉

ការចុះបញ្ជី ត្រូវធ្វើឡើងតាមរយៈ “សេចក្តីសម្រេចបញ្ចប់”
(ម.១៨៩ កថា.១ ចំណុច ច នៃក.ន.រ)
(ប្រការ២ កថា.២, ប្រការ៤០ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី)

↓ ហេតុនេះ

នៅក្នុង “សេចក្តីសម្រេចបញ្ចប់” តុលាការ ត្រូវសរសេរអំពី “ខ្លឹមសារត្រឹមត្រូវសម្រាប់ការចុះបញ្ជី”។
ដើម្បីជាមូលដ្ឋាន, នៅក្នុង “ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ” (ម.៧៥ កថា.២ ចំណុច ខ នៃក.ន.រ) ភាគីក៏ត្រូវសរសេរអំពី “ខ្លឹមសារត្រឹមត្រូវសម្រាប់ការចុះបញ្ជី” ដែរ

↓

# ១ “ចុងចម្លើយ”

↓

“ខ្លឹមសារត្រឹមត្រូវសម្រាប់ការចុះបញ្ជី” សំដៅទៅលើ “ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី”

↓

ចំណុច ១ នៃ “ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី” គឺ “បុគ្គលមានកាតព្វកិច្ចចុះបញ្ជី” (ប្រការ ២៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ដូច្នេះ

ការសរសេរពាក្យថា “ចុងចម្លើយ” ដែលជា “បុគ្គលមានកាតព្វកិច្ចចុះបញ្ជី” មានភាពចាំបាច់

# ២. "ទៅឲ្យដើមចោទ"

〈មូលហេតុ ១〉

ចំណុច ១ នៃ "ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី" គឺ "បុគ្គលមានសិទ្ធិចុះបញ្ជី" (ប្រការ ២៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ដូច្នេះ

ការសរសេរពាក្យថា "ដើមចោទ" ដែលជា "បុគ្គលមានសិទ្ធិចុះបញ្ជី" មានភាពចាំបាច់

# ២. "ទៅឲ្យដើមចោទ"

〈មូលហេតុ ២〉

បណ្ដឹងទាក់ទងនឹងការចុះបញ្ជី គឺជាបណ្ដឹងទាមទារ "ការបង្ហាញឆន្ទៈ" ដែលជាការបង្ហាញឆន្ទៈដាក់ពាក្យសុំចុះបញ្ជី ពីភាគីម្ខាងទៀតដែលមិនព្រមដាក់ពាក្យសុំរួម។

↓ ហេតុនេះ

"ការបង្ហាញឆន្ទៈ" ត្រូវបញ្ជាក់ថា តើអ្នកណា បង្ហាញឆន្ទៈ "ទៅឲ្យអ្នកណា"

↓ ដូច្នេះ

ការសរសេរពាក្យថា "ទៅឲ្យ" មានភាពចាំបាច់

# ៣ 〝ដីដែលបានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុ〞

〈មូលហេតុ〉

ចំណុច ១ នៃ 〝ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី〞 គឺ
〝អត្តសញ្ញាណនៃអចលនវត្ថុ〞 (ប្រការ ២៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ឧទាហរណ៍

ករណីចុះបញ្ជីផ្ទេរកម្មសិទ្ធិ
〝ទីតាំងដី〞 〝លេខក្បាលដី ឬ លេខប័ណ្ណ〞 (ប្រការ ២៨ ចំណុច ង នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)
※គួរតែបង្កើតឧបសម្ព័ន្ធកម្មវត្ថុ ដើម្បីងាយយល់

↓ ដូច្នេះ

ការសរសេរថា 〝ដីដែលបានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុ〞 ដើម្បីកំណត់អចលនវត្ថុ មានភាពចាំបាច់

# ឧទាហរណ៍នៃឧបសម្ព័ន្ធកម្មវត្ថុ ( កម្ពុជា )

※យោងការសរសេរនៅក្នុងសៀវភៅចុះបញ្ជី

## ឧបសម្ព័ន្ធកម្មវត្ថុ

ឈ្មោះរាជធានី/ខេត្ត

ឈ្មោះក្រុង/ស្រុក/ខណ្ឌ

ឈ្មោះឃុំ/សង្កាត់

ឈ្មោះភូមិ

( លេខប័ណ្ណ )

លេខក្បាលដី

ឈ្មោះកម្មសិទ្ធិករ

# ឧទាហរណ៍នៃឧបសម្ព័ន្ធកម្មវត្ថុ (ជប៉ុន)

※ស្របតាមខ្នង់ "អត្តសញ្ញាណដី" នៃសៀវភៅចុះបញ្ជី

## ឧបសម្ព័ន្ធកម្មវត្ថុ

ទីតាំង Osakashi, Fukushimaku, Fukushima 1cyome

លេខក្បាលដី លេខ ១, ៦០

គោលបំណងដី ដីលំនៅដ្ឋាន

ផ្ទៃក្រឡាដី ១២៣.៤៥ម២

## ៤ "ដោយមូលហេតុនៃការលក់ទិញចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣"

〈មូលហេតុ〉

ចំណុច ១ នៃ "ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី" គឺ "មូលហេតុនៃពាក្យសុំចុះបញ្ជី និងកាលបរិច្ឆេទ"
( ប្រការ ២៦ និង ២៨ ចំណុច ៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី )

↓ ហេតុនេះ

ការសរសេរថា "ដោយមូលហេតុនៃការលក់ទិញថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣" ដែលជាមូលហេតុនៃការចុះបញ្ជី មានភាពចាំបាច់

# ៥ ‶(បន្ទាប់)ឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល″

〈មូលហេតុ ១〉

ចំណុច ១ នៃ ‶ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី″ គឺ ‶គោលបំណងនៃពាក្យសុំចុះបញ្ជី″ (ប្រការ ២៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ហេតុនេះ

ការសរសេរថា ‶ចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល″ ដែលជាគោលបំណងនៃការចុះបញ្ជី មានភាពចាំបាច់ (ប្រការ ២៨ ចំណុច ក នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

# ៥ 〝(បន្ទាប់)ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល〞

〈មូលហេតុ ២〉

〝ការចុះបញ្ជី〞 គឺជាការសរសេរនៅក្នុងសៀវភៅចុះបញ្ជី ដែលធ្វើឡើងដោយមន្ត្រីចុះបញ្ជី មិនមែនចុងចម្លើយទេ

(ប្រការ ៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

កិច្ចការដែលចុងចម្លើយអាចធ្វើបាន គឺ 〝ធ្វើនីតិវិធីចុះបញ្ជី〞 មានន័យថាចុងចម្លើយអាចធ្វើបានត្រឹមតែការដាក់ពាក្យសុំចុះបញ្ជីប៉ុណ្ណោះ

(ប្រការ ១០ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ហេតុនេះ

ត្រូវសរសេរថា បង្គាប់ឲ្យ 〝ធ្វើនីតិវិធីចុះបញ្ជី〞 មិនមែន បង្គាប់ឲ្យ 〝ចុះបញ្ជី〞 នោះទេ

# ៥ 〝(បន្ទាប់)ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល〞

〈មូលហេតុ ៣〉

ជាគោលការណ៍ ការដាក់ពាក្យសុំចុះបញ្ជី ត្រូវដាក់រួមគ្នា (ប្រការ ១០ កថា.១ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ករណីលើកលែង

ករណីបុគ្គលមានកាតព្វកិច្ចចុះបញ្ជី មិនព្រមសហការក្នុងការដាក់ពាក្យសុំចុះបញ្ជី

នៅពេលមាន 〝ដីកាសម្រេច ឬសាលក្រម/សាលដីកាស្ថាពរ ដែលជាលិខិតអនុវត្ត បង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី〞 បុគ្គលមានសិទ្ធិចុះបញ្ជីអាចដាក់ពាក្យសុំតែម្នាក់ឯងបាន(កថា.២)

ឧទាហរណ៍៖ 〝សាលក្រម/សាលដីកាស្ថាពរ〞 នៅក្នុងបណ្តឹងចុះបញ្ជី

↓

# ៥ "(បង្គាប់)ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល"

↓ ម្យ៉ាងទៀត

នេះគឺជា "ការបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី" ហេតុនេះ

គឺជាសាលក្រម/សាលដីកា "បង្គាប់ឲ្យផ្តល់តាវកាលិក"(សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី គន្លឹ ៣ ផ្នែកទី ៣ លេខ ១.១)

↓ ហេតុនេះ

គឺជា "សាលក្រម/សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិក"(ម.៣៥០ កថា.២ ចំណុច ក នៃ ក.ន.រ)

↓ ដូច្នេះ

ត្រូវសរសេរថា "បង្គាប់" ឲ្យធ្វើនីតិវិធីចុះបញ្ជី ដែលបង្ហាញថាជាសាលក្រម/សាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិក

សំ.១ តើមិនមានភ្ជាប់ការប្រកាសអនុវត្តបណ្តោះអាសន្នទេ(ម.១៩៦ នៃក.ន.រ)?

ចំ.១ មិនអាចភ្ជាប់ទេ

→ បណ្តឹងចុះបញ្ជី គឺជាបណ្តឹងទាមទារការបង្ហាញឆន្ទៈដែលជាការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជី

→ ពេលសាលក្រម/សាលដីកាចូលជាស្ថាពរ គេសន្មតថាបានបង្ហាញឆន្ទៈ (ម.៥២៩ ក.ន.រ)

→ មុនពេលសាលក្រម/សាលដីកាស្ថាពរ ការកំណត់ថាបានបង្ហាញឆន្ទៈដែលជាការដាក់ពាក្យសុំ "ជាបណ្តោះអាសន្ន" មិនត្រូវបានទទួលស្គាល់នៅក្នុងបញ្ញត្តិច្បាប់ទេ

→មិនអាចភ្ជាប់ការប្រកាសអនុវត្តបណ្តោះអាសន្នដែលជាការអនុវត្តបណ្តោះអាសន្នបានទេ

សំ.២  ការសរសេរថា "A  គឺជាកម្មសិទ្ធិករ" ត្រឹមត្រូវទេ?

ចំ.២  មិនត្រឹមត្រូវទេ

→ នៅក្នុង "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ / សេចក្តីសម្រេចបញ្ចប់" ត្រូវសរសេរនូវ "ខ្លឹមសារត្រឹមត្រូវសម្រាប់ការចុះបញ្ជី"

→ ការសរសេរថា "A គឺជាកម្មសិទ្ធិករ" ពុំមានការបង្គាប់ឲ្យផ្តល់តាវកាលិកអ្វីឡើយ ហេតុនេះវាជាសាលក្រម/សាលដីកាបញ្ជាក់

→ សាលក្រម/សាលដីកាបញ្ជាក់ មិនអាចជាលិខិតអនុវត្តបានទេ

(ម.៣៥០ នៃក.ន.រ មិនបានរៀបរាប់សាលក្រម/សាលដីកាបញ្ជាក់ទេ)

→ ពាក្យសុំអាចដាក់តែម្នាក់ឯងបាន ក្នុងករណីមាន "លិខិតអនុវត្ត" ដែលបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី ដូចជាសាលក្រម/សាលដីកាស្ថាពរ ឬដីកាសម្រេចស្ថាពរ (ប្រការ ១០ កថា.២ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

→ ការសរសេរឃ្លានៅក្នុងសំណួរ មិនមែនជាលិខិតអនុវត្តទេ ហើយមិនអាចចុះបញ្ជីបានទេ ហេតុនេះមិនត្រឹមត្រូវ

សំ.៣  ការសរសេរថា "បង្គាប់ឲ្យមន្ត្រីចុះបញ្ជី ធ្វើការចុះបញ្ជី" ត្រឹមត្រូវដែរ ឬទេ?

ចំ.៣  មិនត្រឹមត្រូវ

→ នៅក្នុង "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ / សេចក្តីសម្រេចបញ្ចប់" ត្រូវសរសេរនូវ "ខ្លឹមសារត្រឹមត្រូវសម្រាប់ការចុះបញ្ជី"

→ បណ្តឹងចុះបញ្ជី គឺជាបណ្តឹងទាមទារការបង្ហាញឆន្ទៈរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ហើយត្រូវចាត់ទុកថាបានបង្ហាញឆន្ទៈ តាមរយៈសាលក្រម/សាលដីកាស្ថាពរ

→ មន្ត្រីចុះបញ្ជី មិនមែនជាបុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជីទេ ហើយក៏មិនមែនជាអ្នកបង្ហាញឆន្ទៈដែរ

→ ការសរសេរឃ្លានៅក្នុងសំណួរ មិនអាចជាការចាត់ទុកថាបានបង្ហាញឆន្ទៈទេ ហើយក៏មិនអាចចុះបញ្ជីបានដែរ ហេតុនេះមិនត្រឹមត្រូវ

# 【ប្រភេទរឿងក្តីដែលត្រូវបង្ហាញ】

១ ការទាមទារឲ្យផ្ទេរការចុះបញ្ជីដោយផ្អែកលើកិច្ចសន្យា

២ ការទាមទារឲ្យលុបការចុះបញ្ជី

៣ ការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ(អចលនវត្ថុ) តាមរយៈការលែងលះ

៤ ការទាមទារឲ្យចុះបញ្ជីដោយផ្អែកលើការបែងចែកមត៌ក

# 【ករណីសិក្សាទី ២】

# ការលក់ ឌិញ្ញូ

## (ការលុបចោលដោយសារការឆបោក)

ករណីសិក្សាទី ២

# ការលក់ទិញដី



A → B



ចុះបញ្ជីកម្មសិទ្ធិ

ទីតាំង សង្កាត់បឹងកេងកង ២ រាជធានីភ្នំពេញ

ទំហំ ៥០០ ម$^{២}$

ថ្ងៃចុះកិច្ចសន្យា ថ្ងៃទី២៨ មករា ២០១៣

តម្លៃ ៥០ម៉ឺនដុល្លារ





ប្រាក់

ករណីសិក្សាទី ២

# ការលក់ទិញដី



A → B





បង់ប្រាក់រួច ⟷ ចុះបញ្ជីរួច

ប្រាក់

ចុះបញ្ជីកម្មសិទ្ធិ

ករណីសិក្សាទី ២

# ការលក់ទិញដី




ថ្ងៃលុបចោល ថ្ងៃទី២ ខែមិនា ឆ្នាំ២០១៣





ខ្ញុំលុបចោលកិច្ចសន្យា ដោយសារមាន
ការឆបោក !
សូមសហការក្នុងការចុះបញ្ជីលុប !

ករណីសិក្សាទី ២

# ការលក់ទិញដី



# ករណីសិក្សាទី ២



A

B





ប្តឹង!

(ទាមទារឲ្យចុះបញ្ជីលុប)

ករណីសិក្សាទី ២



A



B



A ឈ្នះ !

# [ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ／សេចក្តីសម្រេចបញ្ចប់]

បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីទាក់ទងនឹងការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះនៅក្នុងឧបសម្ព័ន្ធចុះបញ្ជី លើដីដែលមានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទ ដោយមូលហេតុនៃការលុបចោលការលក់ទិញនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៣។

ប្រសិនបើធ្វើការវិភាគ...

១ "ចុងចម្លើយ"

២ "ទៅឲ្យដើមចោទ"

៣ "លើដីដែលមានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុ"

៤ "ទាក់ទងនឹងការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះនៅក្នុងឧបសម្ព័ន្ធចុះបញ្ជី"

៥ "ដោយមូលហេតុនៃការលុបចោលការលក់ទិញនៅថ្ងៃទី ២ ខែមីនា ឆ្នាំ២០១៣"

៦ "(បង្គាប់)ឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជី"

១ "ចុងចម្លើយ"

២ "ទៅឲ្យដើមចោទ"

៣ "លើដីដែលមានចុះនៅក្នុងឧបសម្ព័ន្ធកម្មវត្ថុ"

※ប្រការយោង ៖ ប្រការ២៨ ចំណុច ង → ប្រការ៣១ ចំណុច ឃ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី

↓

ដូចគ្នានឹង【ករណីសិក្សាទី ១】ទាំងអស់

## ៤ “ទាក់ទងនឹងការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះនៅក្នុងឧបសម្ព័ន្ធចុះបញ្ជី”

〈មូលហេតុ〉

ដើម្បីចុះបញ្ជីអំពីការលុបការចុះបញ្ជី ចាំបាច់ត្រូវកំណត់កម្មវត្ថុនៃការចុះបញ្ជីអំពីការលុបការចុះបញ្ជី

※ការបង្កើតឧបសម្ព័ន្ធ មានលក្ខណៈងាយយល់។

↓ ហេតុនេះ

ការសរសេរថា “ទាក់ទងនឹងការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះនៅក្នុងឧបសម្ព័ន្ធចុះបញ្ជី” ដើម្បីកំណត់ការចុះបញ្ជី មានភាពចាំបាច់

# ឧទាហរណ៍នៃឧបសម្ព័ន្ធចុះបញ្ជី (កម្ពុជា)

※ផ្អែកតាមការសរសេរនៅក្នុងសៀវភៅចុះបញ្ជី

## ឧបសម្ព័ន្ធចុះបញ្ជី

ឈ្មោះមន្ទីរសុរិយោដី (ថ្នាក់ខេត្ត)
មូលហេតុនៃការចុះបញ្ជី
ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

# ឧទាហរណ៍នៃឧបសម្ព័ន្ធចុះបញ្ជី( ជប៉ុន )

※ស្របតាមខ្ទង់ "ចំណុចទាក់ទងនឹងកម្មសិទ្ធិ" នៃសៀវភៅចុះបញ្ជី

## ឧបសម្ព័ន្ធចុះបញ្ជី

នាយកដ្ឋានកិច្ចការនីតិកម្មទីក្រុងOsaka ទទួលថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៥

ផ្ទេរកម្មសិទ្ធិលេខ ១០០

មូលហេតុ ការលក់ទិញចុះថ្ងៃ១០ ខែមករា ឆ្នាំ២០១៥

កម្មសិទ្ធិករ Tokyoto, Chiyodaku, Kasumigaseki, 1cyome, 1ban, 1gou

Houmu Ichirou

## ៥ “ដោយមូលហេតុនៃការលុបចោលការលក់ទិញ នៅថ្ងៃទី ២ ខែមីនា ឆ្នាំ២០១៣”

※មូលហេតុនៃការចុះបញ្ជី៖ ការលក់ទិញ → ការលុបចោលការលក់ទិញ

កាលបរិច្ឆេទ៖ ថ្ងៃបង្កើតកិច្ចសន្យា → ថ្ងៃលុបចោល

ប្រការយោង៖ ប្រការ២៨ ចំណុច ខ → ប្រការ៣១ ចំណុច ខ

នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី

↓

ដូច【ករណីសិក្សាទី ១】

# ៦ "(បង្គាប់)ឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជី"

〈មូលហេតុ〉

ចំណុច ១ នៃ "ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី" គឺ "គោលបំណងនៃការដាក់ពាក្យសុំចុះបញ្ជី" (ករណីសិក្សាទី១, ប្រការ ២៦, ប្រការ ៣១ ចំណុច ក នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ហេតុនេះ

ការសរសេរថា "ការចុះបញ្ជីអំពីការលុបការចុះបញ្ជី" មានភាពចាំបាច់

"នីតិវិធីចុះបញ្ជី" → ដូច【ករណីសិក្សាទី ១】〈មូលហេតុ២〉

"បង្គាប់ឲ្យ" → ដូច【ករណីសិក្សាទី ១】〈មូលហេតុ ៣〉



# មេរៀនបន្ត នៅថ្ងៃស្អែក !

# ការបែងចែកប្រភេទរឿងក្ដីទាក់ទងនឹងការចុះបញ្ជី

## មូលដ្ឋាននៃ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ" និង "សេចក្ដីសម្រេចបញ្ចប់" ២



ការិយាល័យស្រាវជ្រាវនីតិកម្មរួម ផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិនៃ

ក្រសួងយុត្តិធម៌

សាស្ត្រាចារ្យច្បាប់ UCHIYAMA Jyun

# 【ប្រភេទរឿងក្តីដែលត្រូវបង្ហាញ】

១ ការទាមទារឲ្យផ្ទេរការចុះបញ្ជីដោយផ្អែកលើកិច្ចសន្យា

២ ការទាមទារឲ្យលុបការចុះបញ្ជី

៣ ការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ(អចលនវត្ថុ) តាមរយៈការលែងលះ

៤ ការទាមទារឲ្យចុះបញ្ជីដោយផ្អែកលើការបែងចែកមត៌ក

【ករណីសិក្សាទី ៣】

# ការបែងចែកទ្រព្យសម្បត្តិ

# ( អចលនវត្ថុ )

ករណីសិក្សាទី ៣

# ការបែងចែកដី



A ← B

ទីតាំង  សង្កាត់វត្តភ្នំ ភ្នំពេញ

លទ្ធកម្មក្នុងអំឡុងពេល
អាពាហ៍ពិពាហ៍ → រួម
(ម.៩៧៣ នៃក.រ)



ចុះបញ្ជីកម្មសិទ្ធិអវិភាគ
របស់ A និង B



លែងលះ

កំណត់ថា…

## ករណីភាគីបានព្រមព្រៀងគ្នា

ដី → B

ការចុះបញ្ជីផ្ទេរចំណែកពី A ទៅ B៖ ដូចគោលការណ៍ ដាក់ពាក្យសុំ "រួមគ្នា"
( ប្រការ១០ កថា.១ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី )

↓ ប៉ុន្តែ

ដោយសារមានការព្រមព្រៀង ហេតុនេះពុំចាំបាច់ដាក់ពាក្យបណ្តឹងទៅតុលាការទេ
=មិនមែនជាបញ្ហានៃការសរសេរ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ/សាលក្រមចុងក្រោយ" នោះទេ

អញ្ចឹង,

## តើករណីភាគីពុំបានព្រមព្រៀងគ្នា ទៅជាយ៉ាងណា ?

# ការបែងចែកដី



ករណីសិក្សាទី ៣

# ការបែងចែកដី




មិនអាចប្រគល់ដីឲ្យទេ!
ហើយក៏មិនសហការចុះបញ្ជីផ្ទេរចំណែកដែរ!

# ករណីសិក្សាទី ៣



A



B





ប្ដឹង!
(លែងលះ)

# ករណីសិក្សាទី ៣



A



B



B ឈ្នះ!

# [ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ／សេចក្ដីសម្រេចបញ្ចប់]

១.ធ្វើការបែងចែកទ្រព្យសម្បត្តិរួមរបស់ភាគីទាំង២ដូចតទៅ៖

(១) ធ្វើលទ្ធកម្មដីខាងលើឲ្យទៅដើមចោទ

២. បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិចំណែកទាំងមូលលើដីខាងលើដែលជាកម្មសិទ្ធអវិភាគពាក់កណ្ដាលរបស់ចុងចោទទៅឲ្យដើមចោទដោយមូលហេតុការបែងចែកទ្រព្យសម្បត្តិ។

ប្រសិនបើធ្វើការវិភាគ...

១ "ដីដែលមានចុះក្នុងឧបសម្ព័ន្ធទ្រព្យសម្បត្តិរួម"

២ "ធ្វើការបែងចែកដូចខាងក្រោម"

---

៣ "ដើមចោទ"

៤ "ធ្វើលទ្ធកម្មលើដីខាងលើ"

**១ "ដីដែលមានចុះក្នុងឧបសម្ព័ន្ធទ្រព្យសម្បត្តិរួម"**

※ឧបសម្ព័ន្ធកម្មវត្ថុ→ឧបសម្ព័ន្ធទ្រព្យសម្បត្តិរួម

↓

ដូច 【ករណីសិក្សាទី ១】

# ឧទាហរណ៍នៃឧបសម្ព័ន្ធកម្មវត្ថុ (កម្ពុជា)

※យោងការសរសេរនៅក្នុងសៀវភៅចុះបញ្ជី

## ឧបសម្ព័ន្ធកម្មវត្ថុ (ដី)

ឈ្មោះរាជធានី/ខេត្ត

ឈ្មោះក្រុង/ស្រុក/ខណ្ឌ

ឈ្មោះឃុំ/សង្កាត់

ឈ្មោះភូមិ

(លេខប័ណ្ណ)

លេខក្បាលដី

ឈ្មោះកម្មសិទ្ធិករ

ឈ្មោះដើមចោទ          កម្មសិទ្ធិអវិភាគ ១/២

ឈ្មោះចុងចម្លើយ          កម្មសិទ្ធិអវិភាគ ១/២

# ២ "ធ្វើការបែងចែកដូចខាងក្រោម"

〈មូលហេតុ〉

ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យរួម (ម.៩៧៣ នៃក.រ)

↓

តាមរយៈការ "អនុវត្តការបែងចែក" ទ្រព្យសម្បត្តិនៅពេលលែងលះ(ម.៩៨០ កថា.២ នៃក.រ)
ទំនាក់ទំនងសិទ្ធិនឹងមានការផ្លាស់ប្តូរ
(នៅក្នុងករណីសិក្សា នឹងក្លាយជាកម្មសិទ្ធិតែម្នាក់ឯងរបស់ដើមចោទ)

↓ ដូចនេះ

ការសរសេរអំពីការផ្លាស់ប្តូរសិទ្ធិតាមរយៈការបែងចែកថា "ធ្វើការបែងចែកដូចខាងក្រោម" មានភាពចាំបាច់

# ៣ "ដើមចោទ"

〈មូលហេតុ 〉

ចំណុច ១ នៃ "ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី" គឺ "អ្នកមានសិទ្ធិចុះបញ្ជី" (ករណីសិក្សាទី១, ប្រការ ២៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ដូចនេះ

ការសរសេរថា "ដើមចោទ" មានភាពចាំបាច់

# ៤ "ធ្វើលទ្ធកម្មលើដីខាងលើ"

〈មូលហេតុ〉

តាមរយៈការបែងចែកទ្រព្យសម្បត្តិ(ម.៩៨០ នៃក.រ) ទំនាក់ទំនងសិទ្ធិនឹងមានការផ្លាស់ប្តូរ (ដូចចំណុច ២ ខាងលើ)

ក្នុងរឿងក្តីនេះ ទំនាក់ទំនងសិទ្ធិរួមនឹងក្លាយជាកម្មសិទ្ធិតែម្នាក់ឯងរបស់ B

↓ ជាលទ្ធផល

តាមរយៈការដាក់ពាក្យសុំរួមគ្នា អាចធ្វើការស្នើសុំចុះបញ្ជីពីឈ្មោះរួមគ្នាមកឈ្មោះរបស់ Bតែម្នាក់ឯងបាន (សេចក្តីសម្រេចបញ្ចប់២)

↓ ដូចនេះ

ការសរសេរថា "ធ្វើលទ្ធកម្មលើដីខាងលើ" ជាមូលដ្ឋានក្នុងការដាក់ពាក្យសុំចុះបញ្ជីមានភាពចាំបាច់

ប្រសិនបើធ្វើការវិភាគ…

**៥ “ចុងចម្លើយ”**

**៦ “ទៅឲ្យដើមចោទ”**

**៧ “កម្មសិទ្ធអវិភាគពាក់កណ្ដាលរបស់ចុងចោទលើដីខាងលើ”**

**៨ “ដោយមូលហេតុការបែងចែកទ្រព្យសម្បត្តិ”**

**៩ “បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិចំណែកទាំងមូល”**

## **៥ "ចុចចម្លើយ"**

## **៦ "ទៅឲ្យដើមចោទ"**

↓

ដូច 【ករណីសិក្សាទី១】 ទាំងអស់

# ៧ “កម្មសិទ្ធអវិភាគពាក់កណ្តាលរបស់ចុងចោទលើដីខាងលើ”

〈មូលហេតុ 〉

ការសរសេរថា “លើដីខាងលើ” មានភាពចាំបាច់ដើម្បីកំណត់អំពីអចលនវត្ថុ

❖ ប្រការយោង៖ ប្រការ២៨ ចំណុច ង → ប្រការ២៩

ចំណុច ង នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី

ឧបសម្ព័ន្ធកម្មវត្ថុ → ឧបសម្ព័ន្ធទ្រព្យសម្បត្តិរួម (ដូចទំព័រមុន)

↓

ដូច 【ករណីសិក្សាទី១】ទាំងអស់

## ៧ "កម្មសិទ្ធអវិភាគពាក់កណ្ដាលរបស់ចុងចោទលើដីខាងលើ"

↓ ប៉ុន្តែចំពោះកម្មសិទ្ធអវិភាគ

ចំណុច ១ នៃ "ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី" គឺ "នៅពេលមានកម្មសិទ្ធករលើសពី២នាក់ ត្រូវសរសេរអំពីចំណែកនីមួយៗ" (ប្រការ ២៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ដូចនេះ

ការសរសេរថា "កម្មសិទ្ធអវិភាគពាក់កណ្ដាលរបស់ចុងចោទ" ក៏មានភាពចាំបាច់ក្នុងការកំណត់កម្មសិទ្ធអវិភាគដែរ

# ៨ "ដោយមូលហេតុការបែងចែកទ្រព្យសម្បត្តិ"

〈មូលហេតុ 〉

នៅក្នុងមូលហេតុនៃការចុះបញ្ជីនៃប្រការ២៩ចំណុច ខ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី គេមិនបានសរសេរច្បាស់អំពីការបែងចែកទ្រព្យសម្បត្តិទេ ប៉ុន្តែត្រូវបានគេគិតថាត្រូវនឹង"មូលហេតុដែលបានចែងក្នុងបទដ្ឋានគតិយុត្តិផ្សេងទៀត"

↓

ចំណុច ១ នៃ "ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី" គឺ"មូលហេតុនៃការដាក់ពាក្យសុំចុះបញ្ជី និងកាលបរិច្ឆេទ" " (ករណីសិក្សាទី១, ប្រការ ២៦ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ដូចនេះ

ការសរសេរថា "ដោយមូលហេតុការបែងចែកទ្រព្យសម្បត្តិ"មានភាពចាំបាច់

កាលបរិច្ឆេទ៖ ជាធម្មតាគ្មាន

## ៩ "(បង្គាប់)ឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិចំណែកទាំងមូល"

※កម្មសិទ្ធិ៖ ប្រពន្ធ(ផ្អែកតាមសាលក្រម)

ឈ្មោះចុះបញ្ជី៖ កម្មសិទ្ធអវិភាគរបស់ ប្ដី និងប្រពន្ធ

〈មូលហេតុ 〉

ចំណុច ១ នៃ "ព័ត៌មានសំខាន់នៅពេលដាក់ពាក្យសុំចុះបញ្ជី" គឺ "គោលបំណងនៃពាក្យសុំចុះបញ្ជី" (ប្រការ ២៦, ប្រការ ២៩ ចំណុច ក នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី )

↓ ហេតុនេះ

ការសរសេរថា "ចុះបញ្ជីផ្ទេរកម្មសិទ្ធិចំណែកទាំងមូល" ដែលជាគោលបំណងនៃការចុះបញ្ជី មានភាពចាំបាច់

"បង្គាប់" ដូច【ករណីសិក្សាទី ១】〈មូលហេតុ៣〉

"ឲ្យធ្វើនីតិវិធីចុះបញ្ជី" ដូច【ករណីសិក្សាទី ១】〈មូលហេតុ២ 〉

# [ប្រភេទរឿងក្ដីដែលត្រូវបង្ហាញ]

១ ការទាមទារឲ្យផ្ទេរការចុះបញ្ជីដោយផ្អែកលើកិច្ចសន្យា

២ ការទាមទារឲ្យលុបការចុះបញ្ជី

៣ ការទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ(អចលនវត្ថុ) តាមរយៈការលែងលះ

៤ ការទាមទារឲ្យចុះបញ្ជីដោយផ្អែកលើការបែងចែកមត៌ក

# 【ករណីសិក្សាទី ៤-១】

# ការបែងចែកបន្ទុក

ករណីសិក្សា ៤–១

# មត៌ករបស់ឪពុក

ដី ១





ចុះបញ្ជីកម្មសិទ្ធិ

ដី ២





ចុះបញ្ជីកម្មសិទ្ធិ

---

A កូនប្រុស



- មរណភាពថ្ងៃ៤ ខែមេសា ឆ្នាំ២០១៣
- គ្មានមតកសាសន៍
- ម្តាយមរណភាពយូរហើយ
- សន្តតិជន ២រូប(A, B)

លទ្ធកម្មតាមរយៈសន្តតិកម្ម
→កម្មសិទ្ធិអវិភាគ
(ម.១១៤៨ កថា.២ ក.រ)

B កូនស្រី



កំណត់ថា…

<u>ករណីភាគីបានព្រមព្រៀងគ្នា</u>

ដី១ → A

ដី២ → B

ការចុះបញ្ជីផ្ទេរពីឈ្មោះឪពុកទៅ A និងពីឈ្មោះឪពុកទៅ B ៖

ករណីទាំងអស់ ដាក់ពាក្យសុំតែម្នាក់ឯង(ប្រការ ១0 កថា.២ ប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

មានន័យថា ចំពោះ B, A មិនមែនជាបុគ្គលមានកាតព្វកិច្ចចុះបញ្ជីទេ

↓

មិនចាំបាច់ប្ដឹងទៅតុលាការទេ

＝មិនមែនជាបញ្ហានៃការសរសេរ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ／សេចក្ដីសម្រេចចុងក្រោយ" ទេ

អញ្ចឹង,

## តើករណីភាគីពុំបានព្រមព្រៀងគ្នា ទៅជាយ៉ាងណា?

ករណីសិក្សា ៤-១

# មត៌កឪពុក



# ករណីសិក្សា ៤-១



A

B



ដាក់ពាក្យសុំ!
(ការបែងចែកមត៌ក)



ករណីសិក្សា ៤-១






ដី ១ បែងចែកឲ្យ B !



# 【ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ／សេចក្តីសម្រេចបញ្ចប់】

※សាលក្រម→ដីកាសម្រេច

ធ្វើការបែងចែកដីដែលមានចុះក្នុងឧបសម្ព័ន្ធមត៌ក ដូចខាងក្រោម ៖

（១） ដើមចោទ ធ្វើលទ្ធកម្មលើដីខាងលើ។

※ស្តីពីមូលដ្ឋាននៃដីកាសម្រេច

ម.៣ កថា.១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង

ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី, ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗនៃតារាងឧបសម្ព័ន្ធ តុលាការត្រូវសម្រេចសេចក្តីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង។

កថា.២　ការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច។

តារាងឧបសម្ព័ន្ធផ្នែក ៥ លេខ ១៧　ការបែងចែកមត៌ក ដោយយោងតាមបញ្ញត្តិនៃកថា.ទី១ ម.១២៧០（ការបែងចែកដោយតុលាការ）

ប្រសិនបើធ្វើការវិភាគ…

១ "ដីដែលមានចុះក្នុងឧបសម្ព័ន្ធមត៌ក"

២ "ធ្វើការបែងចែកដូចខាងក្រោម"

---

៣ "ដើមចោទ"

៤ "ធ្វើលទ្ធកម្មលើដីខាងលើ"

**១ "ដីដែលមានចុះក្នុងឧបសម្ព័ន្ធមត៌ក"**

※ឧបសម្ព័ន្ធទ្រព្យសម្បត្តិរួម→ឧបសម្ព័ន្ធមត៌ក

**២ "ធ្វើការបែងចែកដូចខាងក្រោម"**

※ការបែងចែកទ្រព្យសម្បត្តិ→ការបែងចែកមត៌ក

(ម.១២៧០ កថា.២ នៃក.រ)

**៣ "ដើមចោទ"**

↓

ដូច【ករណីសិក្សា ៣】

## ៤ "ធ្វើលទ្ធកម្មលើដីខាងលើ"

〈មូលហេតុ〉

តាមរយៈការបែងចែកមត៌ក(ម.១២៧០ នៃក.រ) ទំនាក់ទំនងសិទ្ធិនឹងមានការផ្លាស់ប្តូរ

ក្នុងករណីសិក្សានេះ ទំនាក់ទំនងសិទ្ធិអវិភាគ ក្លាយទៅជាកម្មសិទ្ធិរបស់ B តែម្នាក់ឯង

↓ ជាលទ្ធផល

អាចដាក់ពាក្យសុំចុះបញ្ជីពីឈ្មោះឪពុកទៅ B តែម្នាក់ឯងបាន

❖ ក្នុងករណីនេះការសរសេរមូលហេតុនៃការដាក់ពាក្យសុំគឺការបែងចែកមត៌ក" (ប្រការ ២៦, ប្រការ២៨ ចំណុច ខ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

↓ ដូចនេះ

ជាមូលដ្ឋានក្នុងការដាក់ពាក្យសុំចុះបញ្ជី

ការសរសេរថា "ធ្វើលទ្ធកម្មលើដីខាងលើ" មានភាពចាំបាច់

សំ. ដូចករណីការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ តើចាំបាច់ត្រូវសរសេរថា "បង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរ" ក្នុងករណីការបែងចែកមត៌កដែរ ឬទេ ?

ចំ. មិនចាំបាច់ទេ

→ លទ្ធកម្មសិទ្ធិតាមរយៈការបែងចែកមត៌ក មានអានុភាពប្រតិសកម្មចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម(ម.១២៧៣ កថា.១ នៃក.រ) ហេតុនេះមិនមែនធ្វើលទ្ធកម្មសិទ្ធិពីសហសន្តតិជននោះទេ (សហសន្តតិជន មិនមែនជាបុគ្គលមានកាតព្វកិច្ចចុះបញ្ជីទេ)

→ មិនចាំបាច់ទាមទារការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជីរបស់សហសន្តតិជនទេ

អាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន(ប្រការ១០ កថា.២ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី)

→ ការសរសេរនៅក្នុងសំណួរ មិនចាំបាច់

# 【ករណីសិក្សា ៤-២】

# អគ្គីយធាន

ករណីសិក្សា៤-២

# មត៌ករបស់ឪពុក

ដី២





ចុះបញ្ជីកម្មសិទ្ធិ

ដី៣





ចុះបញ្ជីកម្មសិទ្ធិ

អច្ច័យទាន

B ប្រពន្ធ



•មរណភាពថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៣
អច្ច័យទាន៖ ពាក្យសុំរួម
(ប្រការ១០ កថា.២ នៃប្រកាសអន្តរក្រសួងទាក់ទងនឹងក្រមរដ្ឋប្បវេណី "ករណីអច្ច័យទានត្រូវអនុវត្តដូចចំណុច ១នៃប្រការនេះ")

C មិត្តភក្តិ



ករណីសិក្សា៤-២

# មត៌ករបស់ឪពុក

ដី២





ដី៣





អច្ច័យទាន

B



C



ចង់ឲ្យសហការក្នុងការចុះបញ្ជីផ្ទេរ !

ដីនេះ មិនប្រគល់ឲ្យទេ !
ក៏មិនសហការក្នុងការចុះបញ្ជីផ្ទេរដែរ !

# ករណីសិក្សា៤-២





B

C



ប្តឹង !

(ទាមទារឲ្យចុះបញ្ជីផ្ទេរ)



# ករណីសិក្សា៤-២



B



C ឈ្នះ !

C



# [ខ្លឹមសារនៃសាលក្រមដែលដើមចោទឈ្នះក្តី ／សេចក្តីសម្រេចបញ្ជប់]

បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលមានចុះក្នុងឧបសម្ព័ន្ធកម្មវត្ថុទៅឲ្យដើមចោទដោយមូលហេតុអច្ច័យទានថ្ងៃទី ៤ ខែមេសា ឆ្នាំ២០១៣។

ប្រសិនបើធ្វើការវិភាគ···

១ "ចុងចម្លើយ"

២ "ទៅឲ្យដើមចោទ"

៣ "លើដីដែលមានចុះក្នុងឧបសម្ព័ន្ធកម្មវត្ថុ"

៤ "ដោយមូលហេតុអច្ច័យទានថ្ងៃទី ៤ ខែមេសា ឆ្នាំ២០១៣"

៥ "(បង្គាប់)ឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល"

**១ “ចុះចម្លើយ”**

**២ “ទៅឲ្យដើមចោទ”**

**៣ “លើដីដែលមានចុះក្នុងឧបសម្ព័ន្ធកម្មវត្ថុ”**

**៤ “ដោយមូលហេតុអច្ច័យទានថ្ងៃទី ៤ ខែមេសា ឆ្នាំ២០១៣”**

※មូលហេតុនៃការចុះបញ្ជី៖ ការលក់ទិញ → អច្ច័យទាន

កាលបរិច្ឆេទ៖ ថ្ងៃចុះកិច្ចសន្យា → ថ្ងៃសន្តតិកម្ម

**៥ “(បន្ទាប់)ឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល”**

↓

ដូច 【ករណីសិក្សាទី ១】ទាំងអស់





# សូមអរគុណ

International Cooperation Department
Research and Training Institute
Ministry of Justice of Japan

4th Floor, Osaka Nakanoshima National Government Building,
1-1-60 Fukushima, Fukushima-ku, Osaka City 553-0003
Phone: 81-6-4796-2153 Fax: 81-4796-2157
E-mail: icdmoj@moj.go.jp